# សមាគមច្បាប់អន្តរជាតិនៃកម្ពុជា

អត្ថបទស្រាវជ្រាវទី២

****

# កាតព្វកិច្ចក្រោមសន្ធិសញ្ញាសិទ្ធិមនុស្ស

## (ប្រភេទ និងបញ្ហាពាក់ព័ន្ធផ្សេងៗទៀត)

**ដោយបណ្ឌិត មាស បូរ៉ា***

(ខែ សីហា ឆ្នាំ ២០២១)

*លោក មាស បូរ៉ា ជាអ្នកស្រាវជ្រាវច្បាប់

**សូមយោង៖ មាស បូរ៉ា កាតព្វកិច្ចក្រោមសន្ធិសញ្ញាសិទ្ធិមនុស្ស៖ ប្រភេទ និងបញ្ហាពាក់ព័ន្ធផ្សេងៗទៀត សមាគមច្បាប់អន្តរជាតិនៃកម្ពុជា ខែសីហា ឆ្នាំ២០២១

***អ្នកនិពន្ធសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះលោកបណ្ឌិត ឡុង សារ៉ាពេជ្រ លោកគង់ សុវណ្ណរង្សី និង លោក នូ ចន្ថា សមាគមច្បាប់អន្តរជាតិនៃកម្ពុជា ដែលបានជួយផ្តល់មតិស្ថាបនាដ៏មានខ្លឹមសារ និងប្រកបដោយភាតរភាព។

## មាតិកា

១. សេចក្តីផ្តើម........................................................................................1

២. កាតព្វកិច្ច..........................................................................................1

២.១. ប្រភេទនៃកាតព្វកិច្ច..........................................................................1

២.១.១. កាតព្វកិច្ចលទ្ធផល និងទង្វើ ..............................................................1

២.១.២. កាតព្វកិច្ចក្រោមវិធានទំនៀមទម្លាប់អន្តរជាតិ .............................................3

២.១.៣. កាតព្វកិច្ចអវិជ្ជមាន និងវិជ្ជមាន..........................................................4

២.១.៤. កាតព្វកិច្ច *erga omnes*...................................................................6

២.២. ចរិតលក្ខណៈនៃកាតព្វកិច្ច....................................................................7

២.៣. ដំណោះស្រាយចំពោះការបំពានកាតព្វកិច្ច ....................................................7

៣. សង្ខេប.............................................................................................9

# ១. សេចក្តីផ្តើម

នៅពេលរដ្ឋចូលជាភាគីសន្ធិសញ្ញាអ្វីមួយដូចជា សន្ធិសញ្ញាស្តីពីសិទ្ធិមនុស្ស រដ្ឋមានកាតព្វកិច្ចអនុវត្តតាមដោយសុទ្ធចិត្ត។ កាតព្វកិច្ចក្នុងសន្ធិសញ្ញា ក្រោយមក ត្រូវបានពង្រីកវិសាលភាពតាមរយៈទស្សនៈយល់ឃើញ ឬសេចក្តីសម្រេចរបស់តុលាការជាតិ ឬអន្តរជាតិ។ អាស្រ័យហេតុនេះ វាជាការសំខាន់ដែលអាជ្ញាធររដ្ឋ ត្រូវយល់ដឹងអំពីប្រភេទ កាតព្វកិច្ច និងចរិតលក្ខណៈ ដើម្បីចាត់វិធានការអនុវត្ត ឬឆ្លើយតប នាពេលមានការចោទប្រកាន់អំពីការបំពានកាតព្វកិច្ចជាដើម។

អត្ថបទនេះ មានបំណងបង្ហាញ នូវប្រភេទនៃកាតព្វកិច្ចក្នុងសន្ធិសញ្ញា និងបច្ចុប្បន្នភាព រួមទាំងប្រភព ប្រភេទ និង ចរិតនៃកាតព្វកិច្ច តាមរយៈការសំយោគ និងដកស្រង់ខ្លឹមសារពីអត្ថបទស្រាវជ្រាវ និងយុត្តិសាស្ត្រមួយចំនួន ដើម្បីបង្ហាញឧទាហរណ៍ជាក់ស្តែង ជាចំណេះដឹងជូនដល់អ្នកស្រាវជ្រាវ ក៏ដូចជាអ្នកអនុវត្តផងដែរ។

# ២. កាតព្វកិច្ច

## *២.១. ប្រភេទនៃកាតព្វកិច្ច*

### ២.១.១. កាតព្វកិច្ចលទ្ធផល និងឧទ្ទេស

កាតព្វកិច្ចមានច្រើនប្រភេទ អាស្រ័យទៅតាម បុគ្គលដែលជាម្ចាស់កាតព្វកិច្ច (obligation holder)។ កាតព្វកិច្ចមានចែងក្នុងសន្ធិសញ្ញាពហុភាគី[1] ឬទ្វេភាគី[2]។ កាតព្វកិច្ចទាំងនោះ អាចចងចំពោះតែរដ្ឋ ឬទាំងរូបវន្តបុគ្គលផងដែរ។[3] ទន្ទឹមនឹងនេះ សម្រាប់រដ្ឋមួយ ទោះបីជាអង្គនីតិប្រតិបត្តិបានដឹកនាំការផ្តល់សច្ចាប័នលើសន្ធិសញ្ញាក្តី ក៏អង្គនៃអំណាចដទៃទៀតរបស់រដ្ឋនោះ មានកាតព្វកិច្ចបំពេញតាមសន្ធិសញ្ញាផងដែរ។[4]

---

[1] កាតព្វកិច្ចចែងក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ដូចជាការមិនប្រើកម្លាំងទ័ពដើម្បីដោះស្រាយជម្លោះ, United Nations, *Charter of the United Nations*, 24 October 1945, 1 UNTS XVI, available at: https://www.refworld.org/docid/3ae6b3930.html [accessed 2 August 2021]

[2] កាតព្វកិច្ចចែងឱ្យធ្វើបត្យាប័នបុគ្គលណាមួយ ក្រោមកិច្ចព្រមព្រៀងទ្វេភាគី ស្តីពី បត្យាប័ន។

[3] នៅមុខសាលាក្តីខ្មែរក្រហម (អវតក) ឌុច ត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះការបំពានច្បាប់អន្តរជាតិ។ មានន័យថាគាត់មានកាតព្វកិច្ចគោរពច្បាប់អន្តរជាតិ ក៏ប៉ុន្តែគាត់បានបំពាន ទើបគាត់ទទួលខុសត្រូវ។

[4] UN Human Rights Committee (HRC), *General comment no. 31 [80], The nature of the general legal obligation imposed on States Parties to the Covenant*, 26 May 2004, CCPR/C/21/Rev.1/Add.13, para. 4, available at: https://www.refworld.org/docid/478b26ae2.html [accessed 31 July 2021]

ដើម្បីផ្តល់ភាពងាយស្រួលក្នុងការពិភាក្សា អ្នកនិពន្ធសូមដកស្រង់មាត្រា ២ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ÷

> ១. *រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាគោរព និងធានាជូនបុគ្គលគ្រប់រូបដែលរស់នៅលើទឹកដី និងស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន នូវសិទ្ធិដែលទទួលស្គាល់ដោយកតិកាសញ្ញានេះដោយគ្មានការបែងចែកណាមួយ មានជាអាទិ៍ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងៗទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពដទៃៗទៀតឡើយ។*
>
> ២. *បើមិនទាន់មានចែងក្នុងច្បាប់ដែលមានស្រាប់ ឬក្នុងវិធានការដទៃទៀតទេ រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាចាត់វិធានការចាំបាច់ ស្របតាមនីតិវិធីនៃរដ្ឋធម្មនុញ្ញរបស់ខ្លួន និងស្របតាមបទប្បញ្ញត្តិ ទាំងឡាយនៃកតិកាសញ្ញានេះ ដោយសម្រួលដល់ការអនុម័តវិធានការច្បាប់ ឬវិធានការផ្សេងទៀត ដែលចាំបាច់ ដើម្បីធ្វើឲ្យសម្រេចបាននូវសិទ្ធិទាំងឡាយ ដែលទទួលស្គាល់ដោយកតិកាសញ្ញានេះ*។...[5]

ផ្អែកតាមខ្លឹមសារដកស្រង់ខាងលើ សម្រាប់វិធានការអនុវត្តសន្ធិសញ្ញា គេចែកនូវកាតព្វកិច្ចលទ្ធផល (obligation of result) និងកាតព្វកិច្ចទង្វើ (obligation of conduct)។[6] នៅពេលចូលជាភាគី សភារបស់រដ្ឋ ត្រូវធ្វើច្បាប់ ចូលរួមអនុវត្តសន្ធិសញ្ញា។ នេះជាកាតព្វកិច្ចទង្វើ។ សន្ធិសញ្ញាទាមទារឲ្យធ្វើច្បាប់ នៅពេលរដ្ឋធ្វើច្បាប់រួចរាល់ រដ្ឋបានបំពេញកាតព្វកិច្ចលទ្ធផលហើយ។ កាតព្វកិច្ចទង្វើ ជាដំណើរការមួយដើម្បីសម្រេចកាតព្វកិច្ចលទ្ធផលនៃគោលដៅចុងក្រោយ។ ជាក់ស្តែង សន្ធិសញ្ញា ទាមទារថា បុគ្គលជាជនរងគ្រោះនៃអំពើបំពានសិទ្ធិ មានសិទ្ធិទទួលនូវដំណោះស្រាយមានប្រសិទ្ធភាព (right to effective remedy)។[7] ឧទាហរណ៍ថា បុគ្គលម្នាក់ ត្រូវបានមន្ត្រីពន្ធនាគារធ្វើទារុណកម្ម សិទ្ធិរួចផុតពីអំពើទារុណកម្មរបស់បុគ្គលនោះ ត្រូវបានបំពាន ដូចនេះ គាត់មាន

[5] UN General Assembly, *International Covenant on Civil and Political Rights*, 16 December 1966, United Nations, Treaty Series, vol. 999, p. 171, available at: https://www.refworld.org/docid/3ae6b3aa0.html [accessed 31 July 2021]

[6] កាតព្វកិច្ចនេះ រាប់បញ្ចូលនូវការបង្ការ ស៊ើបអង្កេត កាត់ទោស និងផ្តល់សំណង, Laurens Lavrysen, *positive obligation in the jurisprudence of the Inter-American Court of Human Rights*, available at: https://www.corteidh.or.cr/tablas/r33493.pdf (visited on 2 August 2021)។

[7] ICCPR, *supra* note 5, មាត្រា ២ (៣)។

សិទ្ធិទទួលបានសំណង។ ក្នុងកម្រិតអប្បបរមា ជនរងគ្រោះ ត្រូវទទួលបានសំណងថ្លៃព្យាបាល និង ជំងឺចិត្ត ហើយលើសពីនេះ មន្ត្រីត្រូវទទួលខុសត្រូវរដ្ឋបាល ឬព្រហ្មទណ្ឌថែមទៀត។ ករណីដែលរដ្ឋ ធ្វើសម្រេចបានដូចនេះ មានន័យថា រដ្ឋបានបំពេញតាមកាតព្វកិច្ចលទ្ធផលហើយ។

ការនិយាយ មានភាពងាយស្រួលជាងការធ្វើ។ ជាដំបូង រដ្ឋត្រូវធ្វើច្បាប់ ចាត់ទុកទារុណកម្ម ជាបទល្មើស ទោះបីប្រព្រឹត្តដោយមន្ត្រីរាជការ ហើយជនរងគ្រោះ មានសិទ្ធិទាមទារសំណងជាមុន សិន (នេះជាការងាររបស់នីតិប្បញ្ញត្តិ)។ បុគ្គលប្ដឹង ទៅតុលាការ ស្នើឲ្យពិនិត្យ សម្រេចសេចក្ដី និង ប្រកាសខុសឬត្រូវ និងជូនសំណងដល់ជនរងគ្រោះ (ដែលនេះជាការងាររបស់អង្គតុលាការ)។ ជា ចុងក្រោយ វាទាមទារការអនុវត្តសាលក្រម ឲ្យមានប្រសិទ្ធភាព (ផ្ដល់សំណងជាក់ស្ដែងជូនជនរង គ្រោះ) ដែលនេះ ជាការងាររបស់អង្គនីតិប្រតិបត្តិ។

កាតព្វកិច្ចទាំងពីរប្រភេទអាចជាន់គ្នា និងមានទំនាក់ទំនងគ្នា។ កាតព្វកិច្ចមួយ បម្រើដល់ កាតព្វកិច្ចប្រភេទមួយទៀត។ ក្នុងករណីខ្លះ កាតព្វកិច្ចទាំងពីរនេះ មានដាច់ដោយឡែកពីគ្នាផងដែរ។

អ្នកស្រាវជ្រាវ និងរដ្ឋ មានគំនិតខ្វែងគ្នាពាក់ព័ន្ធនឹងការភ្ជាប់នឹងកាតព្វកិច្ចនេះ។ អ្នកខ្លះ អះអាងថា សន្ធិសញ្ញាស្ដីពីសិទ្ធិសេដ្ឋកិច្ច ទាមទារគ្រាន់តែកាតព្វកិច្ចទង្វើ ដោយយោងលើពាក្យពេចន៍ "*អនុវត្តជាបណ្ដើរ ...តាមលទ្ធភាព...*"។[8] ផ្ទុយទៅវិញ កាតព្វកិច្ចលទ្ធផល ត្រូវបានភ្ជាប់ទៅនឹង កាតព្វកិច្ច មានក្នុងកតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋ ដោយផ្អែកតាមពាក្យ "full realization[9]" ក្នុងន័យ ថា សិទ្ធិទាំងនោះ ត្រូវអនុវត្តភ្លាមនិងឲ្យមានប្រសិទ្ធភាព។

### ២.១.២. កាតព្វកិច្ចក្រោមវិធានទំនៀមទម្លាប់អន្តរជាតិ

កាតព្វកិច្ចមានចែងក្នុងសន្ធិសញ្ញា ចងដល់រដ្ឋ ដែលចូលជាភាគីតែប៉ុណ្ណោះ។ រីឯកាតព្វកិច្ច ក្រោមវិធានច្បាប់ទំនៀមទម្លាប់អន្តរជាតិ (customary international law) ចងដល់រដ្ឋជាស្វ័យប្រវត្តិ (automatic bound) (ជាវិធានមិនមែនក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ និងតម្រូវឲ្យរដ្ឋទទួលស្គា

[8] UN General Assembly, *International Covenant on Economic, Social and Cultural Rights*, 16 December 1966, United Nations, Treaty Series, vol. 993, p. 3, available at: https://www.refworld.org /docid/3ae6b36c0.html [accessed 31 July 2021]

[9] ICCPR, *supra* note 5, មាត្រា ២(៣)។ Shin Hae Bong, *Japan*, pp. 369-370, Dinah Shelton, International Law and Domestic Legal Systems: Incorporations, transformation, and persuasion, 2011, (Dinah Shelton, International Law)។

ល់)។ ឧទាហរណ៍ ការហាមឃាត់អំពើប្រល័យពូជសាសន៍ បង្កើតជាកាតព្វកិច្ចក្រោមវិធានទំនៀមទម្លាប់អន្តរជាតិ។ ដូចនេះ ទោះបីរដ្ឋមិនចូលជាភាគីនៃអនុសញ្ញាប្រឆាំងនឹងអំពើប្រល័យពូជសាសន៍ក្តី រដ្ឋនៅតែមានកាតព្វកិច្ចគោរពជាដរាប។ អ្វីជាបញ្ហា គឺទំនាក់ទំនងរវាងកាតព្វកិច្ចប្រភេទទាំងពីរនេះ។ សហរដ្ឋអាមេរិកអះអាងនៅមុខ តុលាការយុត្តិធម៌អន្តរជាតិ ថាកាតព្វកិច្ចហាមឃាត់ការប្រើកម្លាំងទ័ពក្រោមវិធានទំនៀមទម្លាប់អន្តរជាតិ លែងមានសុពលភាពទៅហើយ នៅពេល ការហាមឃាត់នេះត្រូវបានសរសេរបញ្ចូលក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ ដែលជាសន្ធិសញ្ញាពហុភាគី។[10] តុលាការបដិសេធទឡ្ហីករណ៍អាមេរិក និងបានអះអាងថា កាតព្វកិច្ចក្រោមទំនៀមទម្លាប់អន្តរជាតិ នៅតែបន្តមានសុពលភាព ហើយកាតព្វកិច្ចក្រោមវិធានទាំងពីរប្រភេទនេះ ដើរតួដោយឡែកៗ និងចងកាតព្វកិច្ចដល់រដ្ឋ។[11]

### ២.១.៣. កាតព្វកិច្ចអវិជ្ជមាន និងវិជ្ជមាន

ទាំងកាតព្វកិច្ចក្រោមវិធានសន្ធិសញ្ញា និងវិធានទំនៀមទម្លាប់ ឬកាតព្វកិច្ចលទ្ធផលកាតព្វកិច្ចទង្វើក្តី អាចត្រូវចាត់ជាពីរប្រភេទ÷កាតព្វកិច្ចអវិជ្ជមាន (negative obligation) និងកាតព្វកិច្ចវិជ្ជមាន (positive obligation)។ កាតព្វកិច្ចប្រភេទទី១ មិនទាមទារសកម្មភាពជាក់ស្តែងទេ ប៉ុន្តែគ្រាន់តែជាការរារាំងមន្ត្រីមិនឲ្យបំពានសិទ្ធិ ឬអាជ្ញាធរគ្រាន់តែលើកកម្ពស់សិទ្ធិមនុស្ស តាមរយៈការបង្រៀន ឬសិក្ខាសាលា ជាការគ្រប់គ្រាន់ហើយ។ វាជាកាតព្វកិច្ច មានជាយូរយារមកហើយ ដោយភ្ជាប់នឹងអធិបតេយ្យភាពនៃរដ្ឋ ដែលវិធានច្បាប់អន្តរជាតិ មិនត្រូវលូកជ្រៅចូលដល់កិច្ចការងារផ្ទៃក្នុងរបស់រដ្ឋ។ ពាក្យលើកកម្ពស់ “promotion” ត្រូវបានប្រើ សម្បីនៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ ដើម្បីឆ្លុះបញ្ចាំងកាតព្វកិច្ចអវិជ្ជមាននេះ។[12] ផ្ទុយទៅវិញ កាតព្វកិច្ចវិជ្ជមាន ទាមទារសកម្មភាពបុរេ

---

[10] សហរដ្ឋអាមេរិក នៅពេលប្រកាសទទួលយកយុត្តាធិការរបស់តុលាការយុត្តិធម៌អន្តរជាតិ បានចែងករណីលើកលែងថាបញ្ហា ចែងក្រោមសន្ធិសញ្ញាពហុភាគី មិនស្ថិតក្នុងសមត្ថកិច្ចរបស់តុលាការនេះទេ។ សន្ធិសញ្ញានោះ គឺធម្មនុញ្ញអង្គការសហប្រជាជាតិ ដែលមានចែងហាមឃាត់ការប្រើកម្លាំងទ័ព។ Stephen P. Mulligan, the United States and the “World Court”, available at: https://fas.org/sgp/crs/row/LSB10206.pdf (visited on 2 August 2021)។

[11] *Case Concerning Military and Paramilitary Activities In and Against Nicaragua (Nicaragua v. United States of America);* International Court of Justice (ICJ), 26 November, 1984, para. 73, available at: https://www.refworld.org/cases,ICJ,4023a44d2.html [accessed 31 July 2021]

[12] United Nations, *Charter of the United Nations*, *supra* note 1, Article 1(3)។

សកម្មពីរដ្ឋ (proactive)។ កាតព្វកិច្ចទាញពីការហាមឃាត់អំពើទារុណកម្ម ជាកាតព្វកិច្ចវិជ្ជមាន។ ជាក់ស្តែង នៅពេលលីព័ត៌មាន (មិនចាំបាច់ជនរងគ្រោះប្តឹងឬដាក់ភស្តុតាង) អាជ្ញាធរ ត្រូវធ្វើសកម្មភាព ដូចជាការស៊ើបអង្កេតជាឯករាជ្យ។ មាត្រា១២ ចែងថា÷ *រដ្ឋភាគី ត្រូវធានាថា អាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ធ្វើជាបន្ទាន់នូវការស៊ើបអង្កេតមិនលំអៀងរៀងរាល់លើកនៅពេលមានមូលហេតុសមស្របគួរឱ្យជឿបានថា អំពើទារុណកម្ម ត្រូវបានប្រព្រឹត្តក្នុងដែនដីស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន*។[13]

កាតព្វកិច្ចវិជ្ជមាន ឆ្លុះបង្ហាញនូវពាក្យពេចន៍ដូចជា ពាក្យធានាថា (ensure[14]) ឬការការពារ (protection) ជាដើម។ ឈរលើស្មារតីនេះ វិសាលភាពកាតព្វកិច្ចរបស់រដ្ឋ ត្រូវបានពង្រីក ក្នុងទម្រង់អរូបិយ និងទទួលបានរិះគន់ពីរដ្ឋមួយចំនួន។ តាមខ្លឹមសារនៃយោបល់ទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ រដ្ឋនឹងទទួលខុសត្រូវ ក្នុងករណីដែលខ្លួនបានបណ្តេញ ឬធ្វើបត្យាប័នជនណាមួយ ទៅរដ្ឋផ្សេង ដែលនៅពេលដល់ទីនោះ សិទ្ធិរបស់ពួកគេត្រូវបានបំពាន ដោយអាជ្ញាធរនៃរដ្ឋនោះ (ដូចជាហានិភ័យនៃការរងនូវអំពើទារុណកម្ម)។[15] រដ្ឋក៏នឹងទទួលខុសត្រូវ ចំពោះទង្វើរបស់អាជ្ញាធរខ្លួន ដែលបានបំពានសិទ្ធិនៅក្រៅដែនដី (extraterritorial application of human rights)។ ការដាក់ការទទួលខុសត្រូវនេះ ធ្វើឱ្យរដ្ឋ និង អ្នកស្រាវជ្រាវ ដែលប្រកាន់យកវិធីសាស្ត្របកស្រាយសន្ធិសញ្ញាតឹងរឹង ប្រតិកម្មដោយផ្អែកលើខ្លឹមសារនៃមាត្រា២ ដកស្រង់ខាងលើ (ប្រើពាក្យ "និង" ភ្ជាប់ពាក្យ "ក្នុងដែនដី" និង "យុត្តាធិការ" សម្រាប់ដាក់ឱ្យរដ្ឋណាមួយទទួលខុសត្រូវសម្រាប់ការបំពានសិទ្ធិមនុស្ស)។ ជាចុងក្រោយ កាតព្វកិច្ចវិជ្ជមាន តម្រូវឱ្យរដ្ឋអន្តរាគមចូលក្នុងការងារ

---

[13] UN General Assembly, *Convention Against Torture and Other Cruel, Inhuman or Degrading Treatment or Punishment*, 10 December 1984, United Nations, Treaty Series, vol. 1465, p. 85, article 12, available at: https://www.refworld.org/docid/3ae6b3a94.html [accessed 31 July 2021]

[14] *Id.*, Article 12.

[15] UN General Assembly, *Convention on the Prevention and Punishment of the Crime of Genocide*, 9 December 1948, United Nations, Treaty Series, vol. 78, p. 277, available at: https://www.refworld .org/docid/3ae6b3ac0.html [accessed 31 July 2021]; General comment no. 31, *supra* note 4,para. 12 ។ មាត្រា ៣ បានចែង..គ្មានរដ្ឋភាគីណាមួយត្រូវបណ្តេញ បញ្ជូនទៅវិញ និងធ្វើបត្យាប័នជនណាម្នាក់ទៅកាន់រដ្ឋមួយផ្សេងទៀត បើមានមូលហេតុល្មមនឹងជឿបានថា ជននោះនឹងធ្លាក់ក្នុងគ្រោះថ្នាក់នៃការធ្វើទារុណកម្ម, Torture Convention, *supra* note 13។

ឯកជន ពាក់ព័ន្ធការបំពានសិទ្ធិដោយប្រជាជនស៊ីវិល (រឿងហិង្សាក្នុងគ្រួសារ) តាមរយៈការធ្វើច្បាប់ ឬកែច្បាប់ ដើម្បីឱ្យជនរងគ្រោះ អាចដាក់ពាក្យបណ្ដឹងទាមទារសំណងជាដើម។

ក្នុងសំណុំរឿងបាត់ខ្លួនដោយបង្ខំ តុលាការអន្តរទ្វីបអាមេរិកាំង បានអះអាងអំពីវត្តមាននៃកាតព្វកិច្ចវិជ្ជមាននេះ÷ *ការបំពានសិទ្ធិមនុស្ស...អាចបង្កដោយបុគ្គលឯកជន...នាំឱ្យរដ្ឋទទួលខុសត្រូវ ...ដោយសារកង្វះការប្រឹងប្រែងបង្ការ...*។[16] ក្នុងរឿងក្ដីមួយ តុលាការសិទ្ធិមនុស្សអឺរ៉ុប បានថ្លែងថា÷ *..អាចមានកាតព្វកិច្ចវិជ្ជមានដើម្បីធានាសិទ្ធិជីវិតឯកជន...អាចតាមរយៈការប្រកាន់យកវិធានការធានានូវការគោរពរវាងទំនាក់ទំនងបុគ្គល និងបុគ្គល*។[17]

អ្នកស្រាវជ្រាវ ត្រូវចងចាំថាជាទូទៅ កាតព្វកិច្ចអវិជ្ជមាន និងវិជ្ជមាន ត្រូវតែប្រកាន់យក និងអនុវត្តព្រមគ្នា ដើម្បីឱ្យសិទ្ធិមនុស្ស ត្រូវបានធានា និងគោរពដោយពេញលេញ។

### ២.១.៤. កាតព្វកិច្ច *erga omnes*

បន្ថែមពីលើនេះ កាតព្វកិច្ចខ្លះ មានអានុភាពចងដល់រដ្ឋទាំងអស់ ទោះបីជារដ្ឋទាំងនោះមិនមែនជារដ្ឋភាគីក៏ដោយ។ នេះវាពាក់ព័ន្ធនឹងចរិតនៃកាតព្វកិច្ច និងភាពជាប់ពាក់ព័ន្ធគ្នារវាងប្រភេទនៃកាតព្វកិច្ច។ ការហាមឃាត់អំពើប្រល័យពូជសាសន៍ បង្កើតជាកាតព្វកិច្ចចងដល់រដ្ឋទាំងអស់ (*erga omnes* obligation)[18]។ ក្នុងន័យថា អំពើប្រល័យពូជសាសន៍កើតនៅទីណាក៏ដោយ ទោះបីជនរងគ្រោះមិនមែនជាប្រជាពលរដ្ឋក្ដី គេសន្មត់ថា រដ្ឋនោះក៏ជារដ្ឋរងគ្រោះ ដែលត្រូវចូលរួមបំពេញកាតព្វកិច្ច ដើម្បីបង្ក្រាបអំពើប្រល័យពូជសាសន៍។ ការបំពេញតាមកាតព្វកិច្ចនេះ អាចជាការកាត់ទោសអ្នកទទួលខុសត្រូវ ឬធ្វើបត្យាប័នជននោះ ទៅប្រទេសផ្សេង ដែលមានបំណងដាក់ជននោះឱ្យទទួលខុសត្រូវ (*aut dedere aut judicare*)។[19]

---

[16] *Velásquez Rodríguez Case*, Inter-Am.Ct.H.R. (Ser. C) No. 4 (1988), Inter-American Court of Human Rights (IACrtHR), 29 July 1988, available at: https://www.refworld.org/cases,IACRTHR, 40279a9e4.html [accessed 2 August 2021] កថាខ័ណ្ឌទី ១៧២។

[17] *X and Y v. the Netherlands*, European Court of Human Rights, No. 8978/80, 26 March 1985, កថាខ័ណ្ឌទី២៣។

[18] Genocide Convention, *supra* note 15, មាត្រា ៦ និង ៧។

[19] Antonio Cassese, the Oxford Companion to International Criminal Justice, *Aut Dedere Aut Judicare*, p. 253.

## ២.២. ចរិតលក្ខណៈនៃកាតព្វកិច្ច

កាតព្វកិច្ចខ្លះ មានចរិតធម្មតា ហើយខ្លះទៀតមានចរិតដាច់ខាត (absolute obligation) ដែលការដោះសារ ឬយុត្តិកម្មណាមួយ មិនត្រូវបានទទួលយកឡើយនៅពេលមានការបំពានកាតព្វកិច្ចក្រោយនេះ។ ឧទាហរណ៍ កាតព្វកិច្ចហាមឃាត់អំពើទារុណកម្ម មានចរិតដាច់ខាត ទាញចេញពីសិទ្ធិដាច់ខាតរួចផុតពីអំពើទារុណកម្ម។ មាត្រា ៤ នៃកតិកា ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ចែងអំពីសិទ្ធិដាច់ខាត (non-derogable rights) មួយចំនួន មិនអាចត្រូវបានផ្អាកអនុវត្តទោះបីក្នុងអំឡុងមានគ្រោះអាសន្នជាសាធារណៈ ដូចជាសង្គ្រាមក្តី។[20] ក្នុងន័យនេះ ទោះបីជាមានស្ថានភាពគ្រោះក្តី អាជ្ញាធររដ្ឋ មិនអាចធ្វើទារុណកម្មដើម្បីយកចម្លើយឡើយ។

ទីនេះយើងគួរកត់សម្គាល់ថា វិធានមានឋានៈខ្ពស់បំផុត (*jus cogens* norm)[21] ដែលអាចបង្កើតជាកាតព្វកិច្ចដាច់ខាត។ មាត្រា ១០៣ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ បាននិយាយអំពីឋានានុក្រមនៃកាតព្វកិច្ចអន្តរជាតិ។[22] ក្រៅពីនេះ មិនមានឯកសារណាមួយ ចែងអំពីឋានានុក្រមនៃកាតព្វកិច្ចក្រោមច្បាប់អន្តរជាតិ ក៏ប៉ុន្តែគេអាចសន្និដ្ឋាន ថាមានឋានានុក្រមនៃកាតព្វកិច្ច ដោយប្រយោល។ កាតព្វកិច្ចដាច់ខាត នឹងលប់លើ (prevailing) ក្នុងករណីកាតព្វកិច្ចនេះ ផ្ទុយគ្នានឹងកាតព្វកិច្ចផ្សេងទៀត។

សិទ្ធិរួចផុតពីអំពើទារុណកម្ម ជាសិទ្ធិដាច់ខាត បង្កើតជាកាតព្វកិច្ចដាច់ខាត និងកាតព្វកិច្ច *erga omnes* ហើយការហាមឃាត់នេះជាវិធាន *jus cogens* ផងដែរ។

## ២.៣. ដំណោះស្រាយចំពោះការបំពានកាតព្វកិច្ច

ការបំពានកាតព្វកិច្ច អាចមានសភាពធ្ងន់ធ្ងរ ឬស្រាល ក្នុងករណីមួយ (isolated instance) ឬមានវិសាលភាពទូលំទូលាយ ឬជាប្រព័ន្ធ (widespread or systematic)[23]។ ដូចនេះ ការឆ្លើយ

---

[20] ICCPR, *supra* note 5, មាត្រា ៤។

[21] United Nations, *Vienna Convention on the Law of Treaties*, 23 May 1969, United Nations, Treaty Series, vol. 1155, p. 331, Articles 53 and 64, available at: https://www.refworld.org/docid/3ae6b3a10.html [accessed 31 July 2021]; jus cogens, available at: www.measboralaws.com

[22] UN Charter, *supra* note 12។

[23] Torture Convention, *supra* note 13, មាត្រា ២០។

តបចំពោះការបំពាន ក៏មានវិសាលភាពខុសគ្នាទៅតាមនោះដែរ។ ទោះបីជាយ៉ាងនេះក្តី ការឆ្លើយតាមច្បាប់នឹងមិនខុសគ្នាទេ។ អ្វីខុសគ្នាគឺ ផ្អែកតាមការអនុវត្តជាក់ស្តែង ឬកត្តានយោបាយ។ ជាក់ស្តែង ការបំពានសិទ្ធិរួចផុតពីទារុណកម្ម ទាំងករណីតែមួយ ឬច្រើន សន្ធិសញ្ញា ចែងអំពីវិធានការផ្លូវច្បាប់ដូចគ្នា ការស៊ើបអង្កេត និង យុត្តាធិការសកល (universal jurisdiction)[24]។

ប្រសិនបើមានការបំពានធ្ងន់ធ្ងរ ធ្វើឱ្យពិភពលោករំជួល សកម្មភាពឆ្លើយតបនឹងមានផុសផុល ដែលពេលខ្លះ ក៏មានបង្កប់មកជាមួយនូវនិន្នាការនយោបាយផងដែរ។ ការអនុវត្តការឆ្លើយតបនឹងមិនងាយស្រួលទេ ដែលជួនកាលមូលដ្ឋានផ្លូវច្បាប់ ស្ថិតក្រោមការពិភាក្សាយ៉ាងតឹងតែង។

បញ្ហានេះ ពាក់ព័ន្ធនឹងការបំពានវិធាន *jus cogens* ក្នុងករណីដែលរដ្ឋមួយ បានបំពានសិទ្ធិប្រជាពលរដ្ឋខ្លួនឯងធ្ងន់ធ្ងររហូតចាត់ទុកជាបទល្មើសក្រោមច្បាប់អន្តរជាតិ ដូចជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ។ ដោយមិនទាន់គិតដល់ការជំទាស់ពីអ្វីដែលជាវិធានប្រភេទនេះ បញ្ហាគឺថារដ្ឋ ឬស្ថាប័នណា ដែលមានសមត្ថកិច្ចចាត់វិធានការឆ្លើយតប។ អ្នកស្រាវជ្រាវ រួមទាំងអង្គការសហប្រជាជាតិ បានឯកភាពចែងនូវកាតព្វកិច្ចមួយគឺ កាតព្វកិច្ចការពារ (responsibility to protect)។[25]

ប្រសិនបើយន្តការឆ្លើយតប ក្រោមឆ័ត្ររបស់អង្គការសហប្រជាជាតិ ឬក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិ ត្រូវបានឯកភាព ដើម្បីឆ្លើយតបនឹងការបំពានកាតព្វកិច្ចសិទ្ធិមនុស្សធ្ងន់ធ្ងរ វាមិនជាបញ្ហានោះទេ។ ក៏ប៉ុន្តែ បញ្ហានឹងកើតឡើងនៅពេល រដ្ឋមួយក្រុម បានចូលទៅអន្តរាគមន៍ រហូតពេលខ្លះប្រើកម្លាំងទម្លាក់រដ្ឋាភិបាលដែលបំពានសិទ្ធិ ក្រោមស្លាកសហគមអន្តរជាតិ (international community)។ អ្វីជាបញ្ហាគឺថា តើរដ្ឋចំនួនប៉ុន្មានដែលរួមគ្នា ទើបហៅបានថាជាសហគមអន្តរជាតិ។ ពេលខ្លះ សហគមអន្តរជាតិ អាចតំណាងមកពីនិន្នាការនយោបាយខុសគ្នា អនុវត្តស្តង់ដារពីរ (double standard) ដែលធ្វើឡើងដើម្បីបំបាក់មុខ ក្រុមប្រទេសមាននិន្នាការនយោបាយផ្ទុយពីខ្លួន។

ជាចុងក្រោយ មូលដ្ឋានផ្លូវច្បាប់ ពិតជាពាក់ព័ន្ធនឹងការឆ្លើយតប។ មិនមែនឱ្យតែការបំពាននូវកាតព្វកិច្ចដាច់ខាត ឬ *erga omnes* សុទ្ធតែមានដំណោះស្រាយនោះទេ។ ជាក់ស្តែង អភ័យឯកសិទ្ធិ

---

[24] Meas Bora on universal jurisdiction at www.measboralaws.com.

[25] UN General Assembly, *Implementing the responsibility to protect : report of the Secretary-General*, 12 January 2009, A/63/677, available at: https://www.refworld.org/docid/4989924d2.html [accessed 31 July 2021]

រួចផុតពីបណ្តឹងរដ្ឋប្បវេណីដើម្បីទាមទារសំណង ពីអំពីទារុណកម្ម (វិធានដាច់ខាត) នៅតែមានដែលអាចខ្មាស់ មិនឲ្យជនរងគ្រោះទារសំណងបាន ទោះបី បុគ្គលជាភ្នាក់ងាររបស់រដ្ឋ ដែលបំពានសិទ្ធិរួចផុតទារុណកម្ម ត្រូវបានដាក់ឲ្យទទួលខុសត្រូវព្រហ្មទណ្ឌរួចហើយក្តី។ ស្រដៀងគ្នានេះ ប្រសិនបើគ្មានច្បាប់ផ្តល់យុត្តាធិការឱ្យតុលាការ កាត់ទោសអ្នកប្រព្រឹត្តអំពើទារុណកម្ម ក៏ការបំពានសិទ្ធិរួចផុតពីទារុណកម្មនៅត្រឹមតែជាការបំពាន។ ក្នុងនេះន័យ អ្នកស្រាវជ្រាវ និងតុលាការ បានញែកដាច់ពីគ្នាអំពីវិធានសារធាតុ (substantive norm) និងវិធាននីតិវិធី (procedural norm)។ ក្នុងន័យថា វិធានប្រភេទសំខាន់ ឬដាច់ខាតអ្វីក៏ដោយ ប្រសិនបើគ្មានវិធាននីតិវិធីគាំទ្រទេ វិធាននោះនឹងមានត្រឹមតែនៅលើក្រដាសតែប៉ុណ្ណោះ។

## ៣. សង្ខេប

ប្រភេទ និងចរិតនៃកាតព្វកិច្ចក្រោមសន្ធិសញ្ញាអន្តរជាតិ មានការប្រែប្រួល និងពង្រីកចាកឆ្ងាយយ៉ាងខ្លាំងពីអត្ថន័យដើមក្នុងសន្ធិសញ្ញា តាមរយៈការបកស្រាយ ដែលក្នុងពេលខ្លះ មានលក្ខណៈអរូបិយ។ នេះ ក្នុងន័យផ្តល់តម្លៃលើគោលបំណង នៃសន្ធិសញ្ញាសិទ្ធិមនុស្ស ដែលមានបុគ្គលជាម្ចាស់សិទ្ធិ និងទាមទារឲ្យរដ្ឋភាគីចាត់វិធានការសកម្ម ដោះស្រាយនូវការបំពានសិទ្ធិ មិនត្រឹមតែកើតមានក្នុងដែនដី ឬក្រោមយុត្តាធិការរបស់ខ្លួនទេ ថែមទាំង ទង្វើបំពានសិទ្ធិ ដែលមិនមែនធ្វើឡើងដោយផ្ទាល់ដោយអាជ្ញាធររបស់ខ្លួនទៀតផង។